# ភីលីព ១:១២-២៦
# រស់សំរាប់ព្រះគ្រីស្ទ

សូមអានភីលីព ១:១២-២៦ ទាំងមូល
សូមអាន ខ១២ ម្តងទៀត
**ការរំលឹក** ស្ថានភាពរបស់លោកប៉ុលគឺគាត់ជាប់គុក។ តើលោកប៉ុលជឿថា ការទាំងប៉ុន្មានដែលកើតឡើងដល់គាត់ មានប្រយោជន៍ដូចម្តេចខ្លះ? (ខ១២)

សូមអាន ខ១៣-១៤។
ការជាប់គុករបស់លោកប៉ុលបានប្រែទៅជាចម្រើនដល់ដំណឹងល្អវិញយ៉ាងដូចម្តេច
ខ១៣-
ខ១៤-

**ការជជែកគ្នា** តើអ្នកធ្លាប់ឃើញគ្រីស្ទបរិស័ទបំរើព្រះគ្រីស្ទយ៉ាងស្មោះត្រង់ក្នុងស្ថានភាពដែលគេទទួលការបៀតបៀនឬទេ? តើគំរូរបស់គ្រីស្ទបរិស័ទនោះបានលើកទឹកចិត្តគ្រីស្ទានយ៉ាងដូចម្តេច

សូមអាន ខ១៥-១៧
លោកប៉ុលបានពិពណ៌នាអំពីហេតុផល រឺ មូលហេតុពីរដែលជំរុញអោយមនុស្សប្រកាសដំណឹងល្អ តើមូលហេតុពីរនោះគឺជាអ្វី?

សូមអាន ខ១៨
តើ នៅក្នុងខ១៨ លោកប៉ុលសំដែងអាកប្បកិរិយាយ៉ាងណាចំពោះស្ថានភាពដែលគាត់ពិពណ៌នានៅក្នុងខ១៥-១៧?

**ការពន្យល់ និង អនុវត្តន៍** នៅក្នុងកណ្ឌភីលីពលោកប៉ុលបានសរសេរច្រើនដងអំពីអំណរ នេះជាផ្ទៃរឿងរឿងធំនៅក្នុងសំបុត្រនេះ។ នេះបង្ហាញថា អ្វីដែលសំខាន់សំរាប់លោកប៉ុលមិនមែនជាសេរីភាពរបស់ខ្លួននោះទេ ប៉ុន្តែគាត់បានដាក់ដំណឹងល្អរបស់ព្រះគ្រីស្ទមានតម្លៃខ្ពង់ខ្ពស់បំផុតវិញ តើយើងបានរៀនអ្វីខ្លះពីគំរូរបស់លោកប៉ុល?

សូមអាន ខ១៩-២០

តើ អ្វីទៅជាគោលបំណងរបស់លោកប៉ុលនៅក្នុងជីវិតរបស់គាត់?

តើ លោកប៉ុលអាចលើកតម្កើងព្រះគ្រីស្ទនៅក្នុងសេចក្ដីស្លាប់របស់គាត់យ៉ាងដូចម្ដេច?

សូមអាន ១២១
នៅក្នុងអត្ថបទនេះលោកប៉ុលសរសេរថា ‹‹ហើយដែលស្លាប់ទៅ នោះជា_______វិញ››

**ការពន្យល់ និង អនុវត្តន៍** តាមធម្មតាមនុស្សគិតថាអនិច្ចកម្មគឺជាពេលដែលយើងខាតបង់ទាំងអស់ ដូច្នេះហើយគេឥតមានទស្សនៈដែលគិតថាសេចក្ដីស្លាប់គឺជាកំរៃទេ។ ដូច្នេះអាកប្បកិរិយារបស់លោកប៉ុលដែលថា ‹‹ហើយដែលស្លាប់ទៅ នោះជា*កំរៃ*វិញ›› នឹងធ្វើឲ្យមនុស្សភ្ញាក់ផ្អើល លោកប៉ុលអាចគិតបែបនេះបានពីព្រោះគាត់ដឹងថាព្រះគ្រីស្ទមានតម្លៃខ្ពង់ខ្ពស់បំផុត ជីវិតរបស់គាត់សំរាប់ព្រះគ្រីស្ទ មិនមែនសំរាប់កម្មសិទ្ធិ ឬអ្វីផ្សេងទៀត។ ប្រសិនបើយើងយកអ្វីដែលមានតម្លៃខ្ពស់ជាងព្រះយេស៊ូវ នោះយើងមិនអាចមានអាកប្បកិរិយាដូចលោកប៉ុលចំពោះអនិច្ចកម្មឡើយ។ តើយើងបានរៀនអ្វីខ្លះពីគំរូរបស់លោកប៉ុល?

សូមអាន ១២២-២៤
តើ ហេតុអ្វីបានជាលោកប៉ុលចង់រស់នៅ

តើ ហេតុអ្វីបានជាលោកប៉ុលចង់ស្លាប់ទៅ?

សូមអាន ១២៥-២៦
លោកប៉ុលដឹងថាគាត់នឹងរស់នៅប្រយោជន៍អ្វី?

**រំលឹកឡើងវិញ** តើអ្នកបានរៀនអ្វីខ្លះពី ភីលីព ១:១២-២៦?

**ការអនុវត្តន៍ និង ជជែកគ្នា** អ្វីដែលយើងបានរៀនតាមរយៈបទគម្ពីរខាងលើនេះ តើយើងត្រូវយកវាមកអនុវត្តន៍ចំពោះខ្លួនអ្នកយ៉ាងដូចម្ដេចនាពេលសព្វថ្ងៃនេះ?
តើអ្នកត្រូវមានការផ្លាស់ប្ដូរជីវិតយ៉ាងម៉េចតាមរយៈមេរៀនចេញពីអត្ថបទនេះ?